# ការតាំងនៅនៃបដិវេធសទ្ធម្ម

## មានរហូតដល់ពុទ្ធសករាជ ៥000 ឆ្នាំ



ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ ប្រសិនណាជាមាតុគ្រាម មិនចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម៌វិន័យដែលតថាគតជ្រាបច្បាស់ហើយទេ ម្នាលអានន្ទ ព្រហ្មចារ្យនឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្មគឺអរហត្តផល ក៏នឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ម្នាលអានន្ទ តែកាលណាមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចារ្យមិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំវិញ ។ ប្រៀបដូចត្រកូល

ទាំងឡាយណានីមួយ ដែលមានស្ត្រីច្រើនមានបុរសតិច ត្រកូលទាំងនោះ ពួកចោរលួចក្អមផ្ទាំ ក៏អាចចូលបំផ្លាញបានដោយងាយ ឬប្រៀបដូចជារោគជាតិ ឈ្មោះសេតដ្ឋិកា (ក្រារ) ធ្លាក់ចុះក្នុងស្រូវស្រែណាដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះ មិនបានតាំងនៅយូរអង្វែងដោយប្រការដូច្នេះ ម្នាលអានន្ទ មាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះមិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចជារោគជាតិ ឈ្មោះមញ្ជេដ្ឋិកា (ដង្កូវក្រារ) ធ្លាក់ចុះក្នុងចម្ការអំពៅណាដែលកំពុងតែលូតលាស់ល្អ ចម្ការអំពៅនោះមិនបានតាំង អង្វែងដោយប្រការដូច្នេះ ម្នាលអានន្ទ គរុធម៌ ៨ ប្រការដែលតថាគតបានបញ្ញត្តហើយ ចំពោះភិក្ខុនីជាដម្បូង ដើម្បីមិនឲ្យ (ភិក្ខុនី) ប្រព្រឹត្តកន្លងដរាបដល់អស់ជីវិត ម្នាលអានន្ទ ប្រៀបដូចជាបុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ ដើម្បីនឹងទប់ទឹកមិនឲ្យហូរចេញ ទៅជាដរាប ។ (វិនយបិដក ចុល្លវគ្គ ភិក្ខុនិក្ខន្ធកៈ ១១/២៧១-២៧២)

## អដ្ឋកថា

ព្រះមានព្រះភាគត្រាស់ថា ***ប្រៀបដូចជាបុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ ដើម្បីនឹងទប់ទឹកមិនឲ្យហូរចេញទៅជាដរាប*** សេចក្តីនេះយ៉ាងណា គរុធម៌ទាំងនេះ ដែលព្រះមានព្រះភាគ ទ្រង់ប្រញាប់បញ្ញត្តទុកមុន ដើម្បីការពារប្រព្រឹត្តកន្លងក្នុងកាលនៅមិនទាន់កើតឡើង ។ កាលគរុធម៌ទាំងនោះ ដែលព្រះមានព្រះភាគ សូម្បីមិនបានបញ្ញត្ត ព្រះសទ្ធម្មនឹងគប្បីតាំងនៅបាន ៥០០ ឆ្នាំ ព្រោះហេតុតែមាតុគ្រាមបួស តែព្រោះហេតុដែលទ្រង់បញ្ញត្តគរុធម៌ទាំងនោះទុកមុន ព្រះសទ្ធម្មនឹងឋិតនៅ ៥០០ ឆ្នាំទៀត សេចក្តីនេះ ក៏យ៉ាងនោះឯង ទើបរួមសេចក្តីថា ព្រះសទ្ធម្មនឹងឋិតនៅរហូត ១០០០ ឆ្នាំ ដែលត្រាស់ដំបូងនោះឯងដោយប្រការដូច្នេះ" ។

តែពាក្យថា "**មួយពាន់ឆ្នាំ**" នោះ ព្រះអង្គត្រាស់ដោយអំណាចព្រះខីណាស្រពដែលដល់ការបែកធ្លាយក្នុងបដិសម្ភិទាប៉ុណ្ណោះ ។

តែកាលនឹងតាំងនៅក្រៃលែងជាងមួយពាន់ឆ្នាំនោះទៀត នឹងតាំងនៅអស់មួយពាន់ឆ្នាំ ដោយអំណាចនៃព្រះខីណាស្រពសុក្ខវិបស្សក: ។

នឹងតាំងនៅអស់មួយពាន់ឆ្នាំទៀត ដោយអំណាចនៃព្រះអនាគាមី ។

នឹងតាំងនៅអស់មួយពាន់ឆ្នាំទៀត ដោយអំណាចនៃព្រះសកទាគាមី ។

នឹងតាំងនៅអស់មួយពាន់ឆ្នាំទៀត ដោយអំណាចព្រះសោតាបន្ន ។

រួមសេចក្តីថា ព្រះបដិវេធសទ្ធម្មនឹងតាំងនៅរហូត ៥ ពាន់ឆ្នាំ ដោយប្រការដូច្នេះ ។ ចំណែកព្រះបរិយត្តិធម៌ នឹងតាំងនៅដូច្នោះដូចគ្នា ។

កាលព្រះបរិយត្តិធម៌មិនមាន បដិវេធនឹងមានក៏ទេ កាលបរិយត្តិមាន បដិវេធនឹងមិនមានក៏ទេ តែកាលបិយត្តិសូម្បីសាបសូន្យទៅហើយ ភេទនឹងប្រព្រឹត្តទៅរហូតអស់កាលយូរដូច្នេះឯង ។

## នៅក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:

ពាក្យថា **ព្រោះហេតុដែលមាតុគ្រាមបួសនេះ** ជាពាក្យសម្តែងហេតុដែលព្រះសទ្ធម្មមិនតាំងនៅលើសជាង ៥០០ ឆ្នាំ និងតាំងនៅបាន ៥០០ ឆ្នាំប៉ុណ្ណោះ ។

ដោយអំណាចព្រះខីណាស្រព ដែលដល់ការបែកធ្លាយក្នុងបដិសម្ភិទាប៉ុណ្ណោះនេះ សូម្បីឈាន ក៏ជាការទ្រង់កាន់យកដោយសព្វថា ព្រះខីណាស្រពអ្នកដល់បដិសម្ភិទានោះ

ឯង ។ ក្នុងគណ្ឋិបទទាំងឡាយតែថា ព្រោះសម្បត្តិគ្រប់ប្រការ រមែងមិនសម្រេចដល់បុគ្គលដែលមិនមានឈាន ។

ពាក្យណាដែលអាចារ្យពោលដោយពាក្យថា **នឹងតាំងនៅអស់ ១ ពាន់ឆ្នាំ ដោយអំណាចព្រះខីណាស្រពសុក្ខវិបស្សក:**ជាដើម ពាក្យនោះ គប្បីជ្រាបថា លោកពោលតាមមតិរបស់អាចារ្យអ្នកពោលគម្ពីរខន្ធក:ទាំងឡាយ ។

**ចំណែកអដ្ឋកថាទីឃនិកាយពោលទុកយ៉ាងនេះថា**

បដិវេធសទ្ធម្មបានតាំងនៅរហូតអស់ ១ ពាន់ឆ្នាំដោយព្រះខីណាស្រពអ្នកសម្រេចបដិសម្ភិទា ។

នឹងតាំងនៅរហូត ១ ពាន់ឆ្នាំទៀតដោយព្រះខីណាស្រពដែលបាន អភិញ្ញា ៦

នឹងតាំងនៅរហូត ១ ពាន់ឆ្នាំទៀតដោយព្រះខីណាស្រពអ្នកសម្រេចវិជ្ជា ៣ ។

នឹងតាំងនៅរហូត ១ ពាន់ឆ្នាំទៀតដោយព្រះខីណាស្រពសុក្ខវិបស្សក: ។

នឹងតាំងនៅរហូត ១ ពាន់ឆ្នាំទៀតដោយព្រះបាតិមោក្ខ ។

**ចំណែកអដ្ឋកថាអង្គុត្តរនិកាយពោលទុកយ៉ាងនេះថា**

អស់ ១ ពាន់ឆ្នាំតាំងអំពីបរិនិព្វានរបស់ព្រះពុទ្ធទាំងឡាយ ព្រះសាវកទាំងឡាយអាចញ៉ាំងបដិសម្ភិទាឲ្យកើត ។

តអំពីនោះអាចញ៉ាំងអភិញ្ញា ៦ ឲ្យកើត ។

តអំពីនោះកាលមិនអាចញ៉ាំងបដិសម្ភិទានិងអភិញ្ញាឲ្យកើត រមែងញ៉ាំងវិជ្ជា ៣ ឲ្យកើត ។

នាកាលកន្លងទៅ កាលមិនអាចញ៉ាំងវិជ្ជា ៣ ឲ្យកើត ក៏ជាសុក្ខវិបស្សក: ។

ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន រមែងតាំងនៅដោយឧបាយនេះឯង ។

**ចំណែកអដ្ឋកថាសំយុត្តនិកាយពោលទុកយ៉ាងនេះថា**

មែនពិត ក្នុងបឋមពោធិកាល ភិក្ខុទាំងឡាយរមែងជាអ្នកបានសម្រេចនូវបដិសម្ភិទា ។

កាលកន្លងទៅ មិនអាចនឹងញ៉ាំងបដិសម្ភិទាឲ្យកើតឡើង ក៏ជាអ្នកបានសម្រេចនូវអភិញ្ញា ៦ ។

តអំពីនោះ កាលមិនអាចញ៉ាំងអភិញ្ញា ៦ ឲ្យកើតឡើង ក៏ជាអ្នកបានសម្រេចនូវវិជ្ជា ៣ ។

ឥឡូវនេះ កាលមិនអាចញ៉ាំងវិជ្ជា ៣ ឲ្យកើតឡើង ក៏ជាអ្នកត្រឹមតែអស់អាសវៈ ។

កាលមិនអាចសម្រេចសូម្បីតែការអស់អាសវៈនោះ ក៏អាចនឹងបានសម្រេចជាព្រះអនាគាមី ។

កាលមិនអាចសម្រេចសូម្បីតែព្រះអនាគាមីនោះ ក៏អាចនឹងបានសម្រេចជាព្រះសកទាគាមី ។

កាលមិនអាចសម្រេចសូម្បីតែព្រះសកទាគាមីនោះ ក៏អាចនឹងបានសម្រេចជាព្រះសោតាបន្ន ។

កាលកន្លងពីនោះទៅ មិនអាចសម្រេចសូម្បីតែសោតាបត្តិផល ។

ពាក្យទាំងអស់នេះ មិនត្រូវគ្នា មានភាពជំទាស់គ្នា ព្រោះហេតុនោះ គប្បីកាន់យកថា ពាក្យទាំងនេះជាមតិរបស់អាចារ្យនោះៗប៉ុណ្ណោះ ។

ក្នុងព្រះសាសនានេះ មានបរិយត្តិជាមូល ព្រោះហេតុនោះ អាចារ្យទាំងឡាយទើបពោលថា កាលបរិយត្តិមិនមាន បដិវេធក៏មិនមាន ។ កាលបរិយត្តិអន្តរធាន បដិបត្តិក៏អន្តរធាន កាលបដិបត្តិអន្តរធាន បដិវេធក៏អន្តរធាន ព្រោះហេតុអ្វី ? ព្រោះថា បរិយត្តិនេះជាបច្ច័យដល់ការបដិបត្តិ ការបដិបត្តិជាបច្ច័យដល់ការបន្ទុះ (បដិវេធ) ។ បរិយត្តិនេះឯងជាប្រមាណសូម្បីជាងការបដិបត្តិ ។ បរិយត្តិនេះឯង ជាប្រមាណនៃការតាំងនៅនៃព្រះសាសនា ព្រោះបណ្ឌិតស្តាប់ព្រះត្រៃបិដកហើយ រមែងញ៉ាំងព្រះសទ្ធម្ម ២ ទៀតឲ្យពេញ ដូចព្រះពោធិសត្វរបស់យើងបានញ៉ាំងអភិញ្ញា ៥ និងសមាបត្តិ ៧ ឲ្យកើតក្នុងសម្នាក់អាឡារតាបស ហើយត្រាស់សួរបរិកម្មនេវសញ្ញានាសញ្ញាយតនសមាបត្តិ អាឡារតាបសឆ្លើយមិនដឹង ។ លំដាប់នោះ ទើបសដេចទៅកាន់សម្នាក់ឧទកតាបស ប្រៀបធៀបគុណវិសេសដែលបានបន្ទុះ ហើយត្រាស់សួរបរិកម្មនេវសញ្ញានាសញ្ញាយតនៈ ឧទកតាបសបានទូលប្រាប់ ។ ព្រះមហាសត្វញ៉ាំងនេវសញ្ញានាសញ្ញាយតនៈឲ្យសម្រេច ក្នុងខណៈដែលឧទកតាបសប្រាប់នោះឯង ។ សេចក្តីនេះយ៉ាងណា ភិក្ខុដែលមានបញ្ញាក៏ដូច្នោះដែរ បានស្តាប់បរិយត្តិហើយ រមែងញ៉ាំងសទ្ធម្ម ២ ទៀតឲ្យពេញបាន ។ ព្រោះហេតុនោះ កាលបរិយត្តិតាំងនៅ ព្រះសាសនាក៏រមែងតាំងនៅ ។ ឧបមាថា ទំនប់ទឹកស្រះធំនៅមាន មិនគួរពោលថា ទឹកនឹងមិនតាំងនៅ កាលមានទឹកតាំងនៅ ក៏មិនគួរពោលថា ផ្កាជលជាតិទាំងឡាយមានផ្កាឈូកជាដើម នឹងមិនមាន ។ សេចក្តីនេះយ៉ាងណា កាលព្រះពុទ្ធវចនៈគឺព្រះត្រៃបិដកដែលប្រៀបដូចទំនប់ទឹករបស់ស្រះធំនៅមាន ក៏មិនគួរពោលថា កុលបុត្រអ្នកប្រព្រឹត្តប្រតិបត្តិដែល

ប្រៀបដូចទឹកក្នុងស្រះធំនោះមិនមាន កាលកុលបុត្រអ្នកប្រព្រឹត្តប្រតិបត្តិទាំងនោះនៅមាន ក៏មិនគួរពោលថា ព្រះអរិយបុគ្គលទាំងឡាយមានព្រះសោតាបន្នជាដើម ដែលប្រៀបដូចផ្កាជលជាតិទាំងឡាយមានផ្កាឈូកជាដើមក្នុងស្រះធំនោះមិនមាន ។

ដោយខេមរ អភិធម្មាវតារ